២- ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាតំណាងជាតិសម្រាប់ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន និងឯកឧត្តម **វង្សី វិស្សុត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកជំនួស ក្នុងករណីអវត្តមានឯកឧត្តមតំណាងជាតិ។

៣- ឯកឧត្តម **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ជាតំណាងជាតិសម្រាប់ក្រុមប្រឹក្សាសហគមន៍សង្គម វប្បធម៌អាស៊ាន និងឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអ្នកជំនួស ក្នុងករណីអវត្តមានឯកឧត្តមតំណាងជាតិ។

**ប្រការពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ថ្មី ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៣ ...ស.ស.រ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ស្វាយរៀង ហ្គីហ្គា វីសស៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច ៤.១ នៃអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ២១៩ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ស្វាយរៀង ហ្គីហ្គា វីសស៍
- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**សម្រេច**

**ប្រការ ១.-** ត្រូវបានបង្កើតរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ស្វាយរៀង ហ្គីហ្គា វីសស៍ ដែលមានទីតាំងស្ថិតនៅភូមិដើមពោធិ៍ ឃុំកណ្ដៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលមានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| ១. តំណាងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា | ប្រធាន |
| ២. តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៣. តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ៤. តំណាងអគ្គនាយកដ្ឋានត្រួតពិនិត្យទំនិញនាំចេញ-នាំចូល និងបង្ក្រាបការក្លែងបន្លំ នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥. តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៦. តំណាងសាលាខេត្តស្វាយរៀង | សមាជិក |

សមាជិករដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ ២.-** រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនេះ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម÷

- ត្រួតពិនិត្យតាមមុខជំនាញសមត្ថកិច្ចចំពោះការចេញពី និងចូលមកនូវទំនិញ មធ្យោបាយ និងជនានុជនគ្រប់រូបរបស់តំបន់។ អនុវត្តការត្រួតពិនិត្យបែបបទគយ សម្រាប់ការចេញ-ចូលទំនិញ និងសម្រួលបែបបទរដ្ឋបាលដល់កិច្ចដំណើរការរបស់តំបន់ ជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ចជំនាញនានា របស់រាជរដ្ឋាភិបាល។
- ត្រួតពិនិត្យការអនុវត្តការងាររបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ លើរាល់សកម្មភាពនៅក្នុងតំបន់ ដោយផ្អែកតាមគោលការណ៍ដែលបានកំណត់។
- ពិនិត្យលើសំណើសុំចុះបញ្ជីវិនិយោគ ពិនិត្យផ្ដល់ជូននូវការលើកទឹកចិត្ត ការចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ វិញ្ញាបនប័ត្រប្រភពដើមទំនិញ ដែលបានស្នើឡើងដោយអ្នកវិនិយោគក្នុងតំបន់ ដើម្បីធ្វើការសម្រេចជូនអ្នកវិនិយោគក្នុងតំបន់ នៅនឹងកន្លែង។
- ធ្វើការត្រួតពិនិត្យការងារសកម្មភាពតាមមុខជំនាញនៅក្នុងតំបន់។
- សហការជាមួយអ្នកអភិវឌ្ឍន៍តំបន់ ដោះស្រាយការងារដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន។
- សម្រួលរាល់បែបបទដែលពាក់ព័ន្ធ ឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព។
- ធ្វើរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ឆមាស និងឆ្នាំ ពីសកម្មភាពរបស់តំបន់ ជូនក្រសួង-ស្ថាប័នគ្រប់គ្រង គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង។
- ធ្វើកិច្ចការផ្សេងៗទៀត ក្នុងការសម្របសម្រួលដោះស្រាយរាល់សំណើរបស់អ្នកវិនិយោគក្នុងតំបន់ ពាក់ព័ន្ធទៅនឹងបណ្ដាក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល។

**ប្រការ ៣.-** គ្រប់តំណាងក្រសួង-ស្ថាប័ន ដែលបំពេញភារកិច្ចនៅក្នុងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ស្វាយរៀង ហ្គីហ្គា វីសស៍ ដូចមានចែងក្នុងប្រការ១ ត្រូវដំណើរការការងារទៅតាមនីតិវិធីនៃច្បាប់ និងបទប្បញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង និងក្រុមហ៊ុន ហ្គីហ្គា វីសស៍ (ខេមបូឌា) ឯ.ក ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៣១០៧...សហវ.ប្រក

ព្រះបរមរាជវាំង

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៧

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការដាក់ឲ្យអនុវត្តអង្គភាពថវិកា

## របស់

## ក្រសួងព្រះបរមរាជវាំង និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យ NS/KRT-34 ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៦ ត្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងដាក់ឲ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឲ្យអនុវត្តនគោលការណ៍ណែនាំ ស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- យោងតាមតម្រូវការចាំបាច់ របស់ក្រសួងព្រះបរមរាជវាំង

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**សម្រេច**

**ប្រការ ១**

ទទួលស្គាល់ និងដាក់ឲ្យអនុវត្តអង្គភាពថវិកាចំនួន ០១ របស់ក្រសួងព្រះបរមរាជវាំង (ដូចមានជូនភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធ) ។

**ប្រការ ២**

ប្រកាសនេះមានប្រសិទ្ធភាពសម្រាប់ការអនុវត្ត ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៧ តទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឋានៈ**
**ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង**

គង់ សំអុល

**ចម្លងជូនៈ**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះបរមរាជវាំង

ព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE

**ការគ្រប់គ្រងថវិកាកម្មវិធី ឆ្នាំ២០១៧**

**រចនាសម្ព័ន្ធ និងការទទួលខុសត្រូវលើកម្មវិធី**

| បរិយាយ | មុខងារទទួលខុសត្រូវ | ការពណ៌នាអំពីការទទួលខុសត្រូវ (កម្មវិធី-អនុកម្មវិធី) | ផ្សេងៗ |
|---|---|---|---|
| ១. កម្មវិធី : ដង្ហែតាម និងបម្រើថ្វាយ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គបំពេញ ព្រះរាជកិច្ច ព្រះរាជតួនាទី បានល្អបំផុត ជា **ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង **សម្ដេចព្រះមហាក្សត្រី នរោត្ដម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ សុភមង្គល បំពេញព្រះរាជកិច្ចទំនាក់ទំនងកិច្ចការទូតជាមួយបណ្ដាប្រទេសជាមិត្តនានាលើសកលលោក , **ព្រះករុណា** បំពេញព្រះរាជកិច្ច ព្រះរាជតួនាទី ជា **ព្រះប្រមុខរដ្ឋ** និងពង្រឹងកិច្ចការហិរញ្ញវត្ថុ សម្របសម្រួលការងាររដ្ឋបាលទូទៅប្រកបដោយប្រសិទ្ធភាព ។ | សម្ដេចចៅហ្វាវាំង គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង | ដង្ហែតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ របស់ **ព្រះមហាក្សត្រ** និង**សម្ដេចព្រះវររាជ-មាតាជាតិខ្មែរ** | |
| ១.១ - អនុកម្មវិធីទី១ : សហការពង្រឹងកិច្ចសហប្រតិបត្តិការ ដោះស្រាយ និងបង្កលក្ខណៈងាយស្រួល ថ្វាយព្រះរាជដំណើរ ថ្វាយ **ព្រះមហាក្សត្រ** និង **សម្ដេចព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងការបំពេញព្រះរាជកិច្ច ជា **ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង **សម្ដេចព្រះវររាជមាតាជាតិខ្មែរ** ។ | ឯកឧត្ដម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង | ដោះស្រាយរាល់ការចំណាយថ្វាយ **ព្រះមហាក្សត្រ** និង**សម្ដេចព្រះវររាជ-មាតាជាតិខ្មែរ** | សម្របសម្រួល ដោយ នាយកដ្ឋានផែនការ-គណនេយ្យ |
| ១.១.១ - ចង្កោមសកម្មភាពទី១ ៖ រៀបចំគ្រប់បែបយ៉ាង តាមសព្វព្រះរាជហឫទ័យ ថ្វាយ **ព្រះមហាក្សត្រ** និង **សម្ដេចព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។ | ឯកឧត្ដម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង | រៀបចំគ្រប់បែបយ៉ាង តាមសព្វព្រះរាជហឫទ័យ ថ្វាយ **ព្រះមហាក្សត្រ** និង **សម្ដេចព្រះវររាជមាតាជាតិខ្មែរ** | |
| ១.១.២- ចង្កោមសកម្មភាពទី២ ៖ រៀបចំ និងផ្គត់ផ្គង់ជាប្រចាំ ក្នុងឱកាស **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** និង **សម្ដេចព្រះវររាជមាតា-ជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត យាងគង់ប្រថាប់នៅក្រៅប្រទេស ដើម្បីពិនិត្យ-ព្យាបាលព្រះរាជសុខភាព និងបំពេញព្រះរាជកិច្ចផ្សេងៗ ។ | ឯកឧត្ដម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង | រៀបចំ និងផ្គត់ផ្គង់ថវិកាជាប្រចាំ ថ្វាយ **ព្រះមហាក្សត្រ** និង**សម្ដេចព្រះវររាជ-មាតា** ឱកាសស្ដេចយាងក្រៅប្រទេស | |
| ១.១.៣- ចង្កោមសកម្មភាពទី៣៖ ការងារថែទាំ និងអភិរក្ស ។ | ឯកឧត្ដម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង | ការងារជួសជុលប្រាសាទ និងព្រះរាជដំណាក់នានា នៅក្នុងក្រសួងព្រះបរមរាជវាំង និងព្រះរាជដំណាក់ នៅតាមខេត្ត នានា | |

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ក្រសួងព្រះបរមរាជវាំង

| បរិយាយ | មុខងារទទួលខុសត្រូវ | ការពណ៌នាអំពីការទទួលខុសត្រូវ (កម្មវិធី-អនុកម្មវិធី) | ផ្សេងៗ |
|---|---|---|---|
| ១.២- អនុកម្មវិធីទី២ : ពង្រឹងកិច្ចសហប្រតិបត្តិការដោះស្រាយ និងបង្កលក្ខណៈងាយស្រួលឲ្យទាន់ពេលវេលា ថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** បំពេញព្រះរាជតួនាទីជា **ព្រះមហាក្សត្រ** និងថ្វាយ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីព្រះអង្គបំពេញ ព្រះរាជកិច្ច លើផ្នែកសង្គមកិច្ច មនុស្សធម៌ វប្បធម៌ សាសនា អង្គការស្ត្រី កាកបាទក្រហម សមាគមន៍ អង្គការក្រៅរដ្ឋាភិបាល និងព្រះរាជកិច្ចទំនាក់ទំនង កិច្ចការទូតជាមួយបណ្តាប្រទេស នានា លើសកលលោក ។ | ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ ទូទៅអមក្រសួងព្រះបរមរាជវាំង | ដោះស្រាយថវិកា និងបង្កលក្ខណៈងាយស្រួល ទាន់ពេលវេលា ថ្វាយ **ព្រះមហាក្សត្រ** និង **សម្តេចព្រះវររាជមាតាជាតិខ្មែរ** ក្នុងការបំពេញព្រះកិច្ច ក្នុងសង្គមជាតិ និងព្រះរាជកិច្ចទំនាក់ទំនង កិច្ចការទូតជាមួយ ប្រទេសនានា លើសកលលោក ។ | សម្របសម្រួល ដោយ នាយកដ្ឋាន ផែនការ-គណនេយ្យ |
| ១.២.១- ចង្កោមសកម្មភាពទី១ ៖ បង្កើនសកម្មភាពការងារ ក្រុមសម្តេចឪ ។ | ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ ទូទៅអមក្រសួងព្រះបរមរាជវាំង | ផ្គត់ផ្គង់ប្រេងឥន្ធនៈជាប្រចាំ, រថយន្តធន់តូច-ធន់ធំ គ្រឿងចក្រធន់តូច-ធន់ធំ និងឧបករណ៍ផ្សេងៗ សម្រាប់បង្កើនការងារក្រុមសម្តេចឪ ដើម្បីចុះជួយប្រជារាស្ត្រ ។ | |
| ១.២.២- ចង្កោមសកម្មភាពទី២ ៖ ការប្រារព្ធព្រះរាជពិធីបុណ្យ តាមទំនៀមទំលាប់ប្រពៃណី ។ | ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ ទូទៅអមក្រសួងព្រះបរមរាជវាំង | រៀបចំព្រះរាជបុណ្យផ្សេងៗ តាមទំនៀម ទំលាប់ប្រពៃណី ។ | |
| ១.២.៣- ចង្កោមសកម្មភាពទី៣ ៖ រៀបចំព្រះរាជបដិសណ្ឋារកិច្ច ថ្វាយ **សម្តេចព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសភ្ញៀវជាតិ-អន្តរជាតិ ចូលក្រាបថ្វាយបង្គំគាល់ ។ | ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ ទូទៅអមក្រសួងព្រះបរមរាជវាំង | រៀបចំព្រះរាជបដិសណ្ឋារកិច្ច ថ្វាយ **សម្តេចព្រះវររាជមាតាជាតិខ្មែរ** ក្នុងឱកាសភ្ញៀវជាតិ-អន្តរជាតិ ចូលក្រាបថ្វាយបង្គំគាល់ ។ | |
| ១.៣- អនុកម្មវិធីទី៣ : ដង្ហែតាមព្រះរាជតម្រិះ ថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គបំពេញព្រះរាជតួនាទី ជា **ព្រះប្រមុខរដ្ឋ** នៃព្រះរាជាណាចក្រកម្ពុជា និងបំពេញព្រះរាជកិច្ច ក្នុងការពង្រឹង និងពង្រីកទំនាក់ទំនងជាតិ-អន្តរជាតិ ។ | ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ ទូទៅអមក្រសួងព្រះបរមរាជវាំង | ដង្ហែតាមព្រះរាជតម្រិះថ្វាយ **ព្រះមហាក្សត្រ** ដើម្បីបំពេញព្រះរាជតួនាទី ជា ព្រះប្រមុខរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា និងបំពេញព្រះរាជកិច្ច ក្នុងការពង្រឹង និងពង្រីកទំនាក់ទំនងជាតិ-អន្តរជាតិ ។ | |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ក្រសួងព្រះបរមរាជវាំង

| បរិយាយ | មុខងារទទួលខុសត្រូវ | ការពណ៌នាអំពីការទទួលខុសត្រូវ (កម្មវិធី-អនុកម្មវិធី) | ផ្សេងៗ |
|---|---|---|---|
| ១.៣.១ -ចង្កោមសកម្មភាពទី១ ៖ រៀបចំព្រះរាជកិច្ចថ្វាយ **ព្រះមហាក្សត្រ** បំពេញព្រះរាជតួនាទីជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដី ។ | ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង | រៀបចំព្រះរាជកិច្ចថ្វាយ **ព្រះមហាក្សត្រ** បំពេញព្រះរាជតួនាទីជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដី ។ | |
| ១.៣.២- ចង្កោមសកម្មភាពទី២ ៖ រៀបចំព្រះរាជបដិសណ្ឋារកិច្ច ថ្វាយ **ព្រះមហាក្សត្រ** ក្នុងឱកាសភ្ញៀវជាតិ-អន្តរជាតិ ចូលក្រាបថ្វាយបង្គំគាល់ ។ | ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង | រៀបចំព្រះរាជបដិសណ្ឋារកិច្ច ថ្វាយ **ព្រះមហាក្សត្រ** ក្នុងឱកាសភ្ញៀវជាតិ-អន្តរជាតិ ចូលក្រាបថ្វាយបង្គំគាល់ ។ | |
| ១.៤ - **អនុកម្មវិធីទី៤** : គាំទ្រ ក្នុងការពង្រឹងការងារផែនការ-គណនេយ្យ និងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និងការសម្របសម្រួលការងារគ្រប់គ្រងរដ្ឋបាលទូទៅ ប្រកបដោយភាពស័ក្តិសិទ្ធិ។ | ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង | ចូលរួមគាំទ្រ និងអនុវត្តន៍ក្នុងការពង្រឹងការងារផែនការ-គណនេយ្យ និងហិរញ្ញវត្ថុ ក៏ដូចជាការសម្របសម្រួលការងារ គ្រប់គ្រងរដ្ឋបាលទូទៅ | សម្របសម្រួល ដោយ នាយកដ្ឋាន ផែនការ-គណនេយ្យ |
| ១.៤.១ - ចង្កោមសកម្មភាពទី១ ៖ ពង្រឹងការងារគ្រប់គ្រង គណនេយ្យភាព-ហិរញ្ញវត្ថុ និងកំណែទម្រង់ប្រកបដោយភាពស័ក្តិសិទ្ធិ ។ | ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង | ចូលរួមការអនុវត្តន៍ការងារគ្រប់គ្រង គណនេយ្យភាព-ហិរញ្ញវត្ថុ និងកំណែទម្រង់ | |
| ១.៤.២ - ចង្កោមសកម្មភាពទី២ ៖ សម្របសម្រួលការងារគ្រប់គ្រងរដ្ឋបាល និងបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព ។ | ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង | ចូលរួមការងារសម្របសម្រួលគ្រប់គ្រងរដ្ឋបាល និងជំរុញឲ្យបណ្តុះបណ្តាលមន្ត្រីរាជការបន្ថែម ។ | |

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០១៧
**សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីធរា**
**ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង**
គង់ សំអុល

បានពិនិត្យ និងពិនិត្យត្រឹមត្រូវ
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០១៧
**ប្រធាននាយកដ្ឋានផែនការ-គណនេយ្យ**
ទីម៉ែន ឫទ្ធី

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០១៧
រៀបចំដោយ
ម៉ុល វ៉ាន់ធី

ឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងលេខ ៣៧៨ សហវ.ប្រក ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE

ព្រះបរមរាជវាំង

# អង្គការលេខអង្គភាពថវិកា
# របស់ក្រសួងព្រះបរមរាជវាំង សម្រាប់ឆ្នាំ ២០១៧




ឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងលេខ [illegible] ចុះថ្ងៃទី 04 ខែ តុលា ឆ្នាំ ២០១៧

ព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE

ព្រះបរមរាជវាំង

## អង្គភាពថវិកា

## របស់ក្រសួងព្រះបរមរាជវាំង ដែលត្រូវបានដាក់ឲ្យអនុវត្ត សម្រាប់ឆ្នាំ ២០១៧

| ល.រ | ឈ្មោះអង្គភាពថវិកា | អង្គភាពអនុវត្ត | | ផ្សេងៗ |
|---|---|---|---|---|
| | | អង្គភាពទទួលខុសត្រូវ | នាយកដ្ឋាន | |
| ១ | **គោលបំណងគោលនយោបាយ៖** ដង្ហែតាម និងបម្រើថ្វាយ **ព្រះមហាក្សត្រ** និង **សម្តេចព្រះវររាជមាតាជាតិខ្មែរ** ព្រះអង្គបំពេញព្រះរាជកិច្ច ព្រះរាជតួនាទីល្អប្រសើរ ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ។ | | | |
| | **ក្រសួងព្រះបរមរាជវាំង** | | | |
| | **កម្មវិធី៖** ដង្ហែតាម និងបម្រើថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គបំពេញ ព្រះរាជកិច្ច ព្រះរាជតួនាទី បានល្អបំផុត ជា **ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សុភមង្គល បំពេញព្រះរាជកិច្ចទំនាក់ទំនងកិច្ចការទូត ជាមួយបណ្តាប្រទេសជាមិត្តនានាលើសកលលោក , ព្រះករុណា បំពេញព្រះរាជកិច្ច ព្រះរាជតួនាទី ជាព្រះប្រមុខរដ្ឋ និងពង្រឹងកិច្ចការហិរញ្ញវត្ថុ សម្របសម្រួលការងាររដ្ឋបាលទូទៅប្រកបដោយប្រសិទ្ធភាព ។ | | | |
| | **អង្គភាពថវិកា១** | ក្រសួងព្រះបរមរាជវាំង | 1- នាយកដ្ឋានរដ្ឋបាល<br>2- នាយកដ្ឋានបុគ្គលិក និងធនធានមនុស្ស<br>3- នាយកដ្ឋានទំនាក់ទំនង<br>4- នាយកដ្ឋានអភិរក្ស<br>5- នាយកដ្ឋានផែនការ-គណនេយ្យ →<br>6- នាយកដ្ឋានដឹកជញ្ជូន<br>7- នាយកដ្ឋានពិធីការ<br>8- នាយកដ្ឋានឧបត្ថម្ភ និងសង្គ្រោះប្រជារាស្ត្រ<br>9- នាយកដ្ឋានសំណង់<br>10- នាយកដ្ឋានគ្រប់គ្រងព្រះរាជដំណាក់ | នាយកដ្ឋាន ផែនការ-គណនេយ្យ ជាអ្នកសម្របសម្រួល |

ឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងលេខ [illegible] ចុះថ្ងៃទី 04 ខែ មេសា ឆ្នាំ ២០១៧

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL • ព្រះបរមរាជវាំង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ...៥៣៣....សហវ.ប្រក

**ប្រកាសអន្តរក្រសួង**
**ស្តីពី**
**ការតែងតាំងភ្នាក់ងារបើកផ្តល់នៅអង្គភាពប្រឆាំងអំពើពុករលួយ**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី**
**ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រង និងការចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត ការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពប្រឆាំងអំពើពុករលួយ

## សម្រេច

**ប្រការ ១.-** ត្រូវបានតែងតាំងមន្ត្រីរាជការនៃអង្គភាពប្រឆាំងអំពើពុករលួយដូចខាងក្រោម ៖

- លោក **ព្រាប សុវណ្ណឌី** ជាភ្នាក់ងារបើកផ្តល់នៅអង្គភាពប្រឆាំងអំពើពុករលួយ
- លោក **ឡឹក ពុំមូរិន** ជាភ្នាក់ងារបើកផ្តល់ជំនួសនៅអង្គភាពប្រឆាំងអំពើពុករលួយ ។

**ប្រការ ២.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣.-** នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអង្គភាពប្រឆាំងអំពើពុករលួយ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០១៧

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ទេសរដ្ឋមន្ត្រី**
**ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ**

**ឱម យ៉ិនទៀង**

កន្លែងទទួលៈ
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងមុខងារសាធារណៈ*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ដូចប្រការ ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] សហវ.[illegible]

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការបង្កើតរង្វាន់បុរេប្រទានសម្រាប់ឆ្នាំ២០១៧ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្រហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យ-បុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨៧៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ១៦២ អយក.ប្រក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ដីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**ប្រការ ១** -

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក៦០"ការទិញ" ជំពូក៦១"សេវាកម្ម" នៅនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨៧៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២** -

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ ៣** -

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤** -

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានឧត្តមសិក្សា ប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ២០១៧

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និង កីឡា**

**បណ្ឌិត ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ
- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អង្គភាពថវិកានាយកដ្ឋានសវនកម្មផ្ទៃក្នុង

## តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន
## ថវិកាកម្មវិធីឆ្នាំ២០១៧ របស់អង្គភាពថវិកានាយកដ្ឋានសវនកម្មផ្ទៃក្នុង

ឯកតាគិតជារៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៧ | ឥណទាន ដែលជ្រើសរើស | ឥណទាន រជ្ជទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន១ដុំបង្វិល រជ្ជទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ដង | ៦=៣/២ |
| | | | សរុប | 805,200,000 | 759,200,000 | 488,700,000 | 270,500,000 | 122,175,000 | 64.4% |
| 60 | | | ការទិញ | 172,800,000 | 132,800,000 | 32,700,000 | 100,100,000 | 8,175,000 | 24.6% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 13,200,000 | 13,200,000 | 13,200,000 | 0 | 3,300,000 | 100.0% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 3,000,000 | 3,000,000 | 3,000,000 | 0 | 750,000 | 100.0% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 6,000,000 | 6,000,000 | 6,000,000 | 0 | 1,500,000 | 100.0% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 4,200,000 | 4,200,000 | 4,200,000 | 0 | 1,050,000 | 100.0% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 110,100,000 | 110,100,000 | 10,000,000 | 100,100,000 | 2,500,000 | 9.1% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 110,100,000 | 110,100,000 | 10,000,000 | 100,100,000 | 2,500,000 | 9.1% |
| | 6003 | | ស្បៀងអាហារនិងផលិតផលកសិកម្ម | 5,000,000 | 5,000,000 | 5,000,000 | 0 | 1,250,000 | 100.0% |
| | | 60031 | ស្បៀង | 5,000,000 | 5,000,000 | 5,000,000 | 0 | 1,250,000 | 100.0% |
| | 6005 | | សម្ភារៈតូចតាច សង្ហារិម និងសម្ភារៈបរិក្ខារ | 44,500,000 | 4,500,000 | 4,500,000 | 0 | 1,125,000 | 100.0% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 40,000,000 | 0 | 0 | 0 | 0 | #DIV/0! |
| | | 60052 | សង្ហារិម | 3,000,000 | 3,000,000 | 3,000,000 | 0 | 750,000 | 100.0% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 1,500,000 | 1,500,000 | 1,500,000 | 0 | 375,000 | 100.0% |
| 61 | | | សេវាកម្ម | 632,400,000 | 626,400,000 | 456,000,000 | 170,400,000 | 114,000,000 | 72.8% |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុងនិងក្រៅប្រទេស | 21,800,000 | 21,800,000 | 21,800,000 | 0 | 5,450,000 | 100.0% |
| | 6105 | | ការថែទាំនិងជួសជុល | 28,700,000 | 28,700,000 | 28,700,000 | 0 | 7,175,000 | 100.0% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 1,500,000 | 1,500,000 | 1,500,000 | 0 | 375,000 | 100.0% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 8,000,000 | 8,000,000 | 8,000,000 | 0 | 2,000,000 | 100.0% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 19,200,000 | 19,200,000 | 19,200,000 | 0 | 4,800,000 | 100.0% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 7,900,000 | 7,900,000 | 7,900,000 | 0 | 1,975,000 | 100.0% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 7,900,000 | 7,900,000 | 7,900,000 | 0 | 1,975,000 | 100.0% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 568,000,000 | 568,000,000 | 397,600,000 | 170,400,000 | 99,400,000 | 70.0% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 57,600,000 | 57,600,000 | 40,320,000 | 17,280,000 | 10,080,000 | 70.0% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៧ | ឥណទាន ដែលជ្រើសរើស | ឥណទាន ផ្ទេរទៅឲ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទានទំរុំបង្វិល ផ្ទេរទៅឲ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥ = ៣/៤ដង | ៦=៣/២ |
| | | 61122 | សោហ៊ុយបេសកកម្ម | 66,000,000 | 66,000,000 | 46,200,000 | 19,800,000 | 11,550,000 | 70.0% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 444,400,000 | 444,400,000 | 311,080,000 | 133,320,000 | 77,770,000 | 70.0% |
| | 6114 | | **សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍** | 6,000,000 | 0 | 0 | 0 | 0 | #DIV/0! |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 6,000,000 | 0 | 0 | 0 | 0 | #DIV/0! |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៧
ជ. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង

មិញ បានសុវណ្ណអានីច្ចាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៧
ជ.អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងអប់រំ យុវជន និងកីឡា

គីន_កោសល្អ

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែមករា ឆ្នាំ២០១៧
ប្រធានអង្គភាពថវិកា
នាយកដ្ឋានសវនកម្មផ្ទៃក្នុង

ស៊ុខ សុហេម៉ា

ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
វិជ្ជាជីវករបុរេប្រទាន

ខេងសុវ៉ត្ថ

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៧
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃទី ខែ ឆ្នាំ២០១៧
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត ហង់ជួន ណារ៉ុន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៩៦៣ សហវ.ប្រក

# ប្រកាស

## ស្តីពី

## វិធាននិងនីតិវិធីសម្រាប់អនុវត្ត ពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេស

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងណែនាំអនុវត្តពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេស ស្របតាមមាត្រា២២ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់ឱ្យបានច្បាស់លាស់នូវវិធាននិងនីតិវិធីសម្រាប់ណែនាំអនុវត្តពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេស ដូចមានចែងក្នុងមាត្រា២២ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសាខាក្រុមហ៊ុនបរទេសដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ពាក្យ "សាខាក្រុមហ៊ុនបរទេស" សំដៅដល់ ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុនបរទេស ដែលក្នុងនោះទ្រព្យសកម្មផ្សេងៗគឺជារបស់ក្រុមហ៊ុនដើមនៅបរទេស។

**ប្រការ ៥.- ប្រាក់ចំណូលជាប់ពន្ធ**

អនុលោមតាមកថាខណ្ឌ៤ នៃមាត្រា៣ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ សាខាក្រុមហ៊ុនបរទេស ត្រូវជាប់ពន្ធលើប្រាក់ចំណូលចំពោះតែប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។ ប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណូលបានមកពីការប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា កាត់កងនូវចំណាយនានាដែលអនុញ្ញាតដោយបទប្បញ្ញត្តិនៃផ្នែកទី៣ នៃជំពូកទី១ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៦.- ការគណនាពន្ធលើប្រាក់ចំណូល**

ពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេសសម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវបានគណនាដោយយកប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធនោះ ទៅគុណនឹងអត្រាពន្ធដូចមានចែងក្នុងមាត្រា២០ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៧.- ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ**

ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធចរន្ត សាខាក្រុមហ៊ុនបរទេសធ្វើការបែងចែកប្រាក់ចំណូលរក្សាទុកទៅឱ្យក្រុមហ៊ុនដើមនៅបរទេស ប្រាក់ចំណូលនោះ÷

១- មិនត្រូវជាប់ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភតាមមាត្រា២៣ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធទេ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលក្រោយការបង់ពន្ធលើប្រាក់ចំណូលតាមកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រា២០ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

២- ត្រូវជាប់ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភតាមកថាខណ្ឌ១ នៃមាត្រា២៣ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលដែលមិនបានបង់ពន្ធលើប្រាក់ចំណូលតាមកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រា២០ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៨.-  ពន្ធកាត់ទុកលើប្រាក់ចំណូលប្រភពកម្ពុជា**

នៅពេលសាខាក្រុមហ៊ុនបរទេសផ្ទេរប្រាក់ចំណូលប្រភពកម្ពុជាទៅឱ្យក្រុមហ៊ុនដើមនៅបរទេស ត្រូវកាត់ទុកនិងបង់នូវប្រាក់ពន្ធចំនួន ១៤ ភាគរយ នៃទឹកប្រាក់ត្រូវផ្ទេរ ស្របតាមមាត្រា២៦ថ្មី (មួយ) និងកថាខណ្ឌ ១០ នៃមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៩.-  ពន្ធអាករដទៃទៀត**

ក្រៅពីពន្ធលើប្រាក់ចំណូល សាខាក្រុមហ៊ុនបរទេសត្រូវបង់ពន្ធអាករដទៃទៀត ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១០.-  កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ**

សាខាក្រុមហ៊ុនបរទេសត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធអាករប្រចាំខែ ប្រចាំឆ្នាំ តាមកាលកំណត់ ជូនរដ្ឋបាលសារពើពន្ធ។

**ប្រការ ១១.-  ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ១១ “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] សហវ.[illegible]

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០[illegible]

**ប្រកាសអន្តរក្រសួង**
**ស្តីពី**
**ការតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួសរបស់ក្រសួងទេសចរណ៍**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញសារាចរណែនាំលេខ០០៤ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីភ្នាក់ងារបើកផ្តល់
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៦/០១៩ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នរ/រកម/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បកចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងកាប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៨១/អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋទៅតាមក្រសួង ខេត្តក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ០០៤ សហវ.ម ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៨៩សហវ.ប្រកចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃការងាររបស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១ ÷** ប្រាក់បៀវត្សមន្ត្រីរាជការ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌នៃក្រសួងទេសណ៍ត្រូវបើកផ្តល់តាមរយៈភ្នាក់ងារបើកផ្តល់។

**ប្រការ២ ÷** ត្រូវបានតែងតាំងភ្នាក់ងារបើកផ្តល់មួយរូប និងភ្នាក់ងារបើកផ្តល់ជំនួស របស់ក្រសួងទេសចរណ៍ដូចមានខាងក្រោមនេះ៖

១-លោកស្រី **សុខ ច័ន្ទនី** ឋានៈអនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ជាភ្នាក់ងារបើកផ្តល់នៃក្រសួងទេសចរណ៍

២-លោកស្រី **ឡាយ ស្រីម៉ាច** ឋានៈអនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ជាភ្នាក់ងារបើកផ្តល់ជំនួសនៃក្រសួងទេសចរណ៍

៣-លោកស្រី **វ៉ាន់ មនិកា** ឋានៈមន្ត្រីជាភ្នាក់ងារបើកផ្តល់ជំនួសនៅក្រសួងទេសចរណ៍

**ប្រការ៣ ÷** លោកស្រី សុខ ច័ន្ទនី ជាភ្នាក់ងារបើកផ្តល់ លោកស្រី ឡាយ ស្រីម៉ាច ជាភ្នាក់ងារបើកផ្តល់ជំនួស នឹង លោកស្រី វ៉ាន់ មនិកា ជាភ្នាក់បើកផ្តល់ជំនួស ត្រូវបានអនុញ្ញាតអោយបើក

គណនីប្រាក់បញ្ញើនៅអគ្គនាយកដ្ឋានរតនាគារជាតិដើម្បីទទួលមូលនិធិសម្រាប់យកទៅបើកប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ជូនមន្ត្រីរាជការ។

**ប្រការ ៤** បែបបទនៃការអនុវត្តបើកផ្តល់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ត្រូវបានកំណត់ដោយសេចក្តីណែនាំជាក្រោយ។

**ប្រការ ៥** ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និង មូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់អោយមន្ត្រីរាជការ។

**ប្រការ ៦** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទទួលជានិរាករណ៍។

**ប្រការ ៧** នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុរបស់ក្រសួងទេសចរណ៍ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារៈកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

| | |
|---|---|
| **ទេសរដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ក្រសួងទេសចរណ៍** |
| បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន** | **ថោង ខុន** |

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible]......សហវ.[illegible]

រាជធានីភ្នំពេញ,ថ្ងៃទី[illegible]..ខែ[illegible]ឆ្នាំ២០១៧

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស របស់ក្រសួងកិច្ចការនារី

**ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/១៣៩៣ចុះថ្ងៃទី០៤ខែមេសាឆ្នាំ២០១៦ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
-បានឃើញព្រះរាជក្រមលេខនស/រកម/១២១៥/១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខនរ/រកម/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្ម មាត្រា៩ និង មាត្រា១០ នៃច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០២ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

-បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
-បានឃើញអនុក្រឹត្យលេខ៨១ អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល
-បានឃើញអនុក្រឹត្យលេខ៨២ អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅគណនេយ្យសាធារណៈ
-បានឃើញប្រកាសលេខ០០៤ សហវ.ម. ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
-បានឃើញប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ
-បានឃើញប្រកាសលេខ២១១ សហវ.ប្រក ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
-យោងតាមតម្រូវការចាំបាច់នៃការងាររបស់ក្រសួងកិច្ចការនារី

## សម្រេច

ប្រការ១ : ប្រាក់បៀវត្សមន្ត្រីរាជការ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌នៃក្រសួងកិច្ចការនារីត្រូវបើកផ្តល់តាមរយៈភ្នាក់ងារបើកផ្តល់។

ប្រការ២ : ត្រូវបានតែងតាំងភ្នាក់ងារបើកផ្តល់ និង ភ្នាក់ងារបើកផ្តល់ជំនួសរបស់ក្រសួងកិច្ចការនារី ដូចមានសមាសភាពខាងក្រោម ៖

-លោកស្រី **សារូ រដ្ឋចរិយា** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ ជាភ្នាក់ងារបើកផ្តល់
-លោកស្រី **ឯក ច័ន្ទនីរ៉ាដា** ប្រធានការិយាល័យបេឡា ជាភ្នាក់ងារបើកផ្តល់ជំនួស

ប្រការ៣: លោកស្រី សារូ រដ្ឋចរិយា ជាភ្នាក់ងារបើកផ្តល់និង លោកស្រី ឯក ច័ន្ទនីរ៉ាដា ជាភ្នាក់ងារបើកផ្តល់ជំនួសត្រូវបានអនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើនៅអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីទទួលមូលនិធិសម្រាប់យកទៅបើកប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ ។

ប្រការ៤ : បែបបទនៃការអនុវត្តបើកផ្តល់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ត្រូវបានកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

ប្រការ៥ :ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ។

ប្រការ៦ :សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

ប្រការ៧: នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ របស់ក្រសួងកិច្ចការនារី ប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ២ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

អ៊ឹង កន្ថាផាវី

**<u>ចម្លងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...............សហវ.............

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតែងតាំងថ្នាក់ដឹកនាំការិយាល័យ របស់អគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាព រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាព រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្ម មាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា៤៤ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បកចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- ប្រកាសលេខ៥៤៤ ប្រក.បស្ថ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិនិងការផ្ទេរឥណទានថវិកា
- បានឃើញប្រកាសលេខ១២ ប្រក.បស្ថ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការតែងតាំងមន្ត្រីអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការ ត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរងរបស់អគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថាន មានសមាសភាពដូចខាងក្រោម ៖

១. លោក **ទា ធីរោ** ឋានៈអនុប្រធាននាយកដ្ឋាន ជារជ្ជទេយ្យករបុរេប្រទាន
២. លោក **ម៉ុក សុភា** ឋានៈអនុប្រធាននាយកដ្ឋាន ជារជ្ជទេយ្យករបុរេប្រទានរង
៣. កញ្ញា **ប៉ុន ចន្ទីដា** ឋានៈមន្ត្រី ជារជ្ជទេយ្យករបុរេប្រទានរង
៤. លោក **អ៊ូ គង់ផល** ឋានៈមន្ត្រី ជារជ្ជទេយ្យករបុរេប្រទានរង

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋានគាំពារបរិស្ថាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថាន ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ[illegible] ឆ្នាំ២០១៧

**ឆ្លងរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...សហវ....

**ប្រកាសអន្តរក្រសួង**
**ស្តីពី**
**ការបង្កើតវង្វេងយុបុរេប្រទានសម្រាប់ឆ្នាំ២០១៧**
**របស់អគ្គនាយកដ្ឋានគាំពារបរិស្ថាន**
**នៃក្រសួងបរិស្ថាន**

**ទេសរដ្ឋមន្ត្រី** **រដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **ក្រសួងបរិស្ថាន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាព រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាព រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៤៤ មាត្រា៤៦ និងមាត្រា៤៧នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញប្រកាសលេខ ៥៣៨ ប្រក.បស្ណ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- ប្រកាសលេខ ៥៤៤ ប្រក.បស្ណ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និងការផ្ទេរឥណទានថវិកា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានគាំពារបរិស្ថាន

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ" និងជំពូក៦១ "សេវាកម្ម" នៅអគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន សម្រាប់មុខចំណាយដូចមានចែងក្នុងប្រការ៥ ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២**.-

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរដ្ឋទេយ្យបុរេប្រទាន ត្រូវកំណត់ដូចតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន។

**ប្រការ៣**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤**.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ របស់អគ្គនាយកដ្ឋានគាំពារបរិស្ថាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថានត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ១៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

**សាយ សំអាល់**

កន្លែងទទួល៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

## តារាងឧបសម្ព័ន្ធវឌ្ឍនេយ្យបុរេប្រទានថវិកាកម្មវិធីឆ្នាំ២០១៧
## របស់អគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន

ឯកតា: ជារៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៧ | ឥណទានដែលត្រូវជ្រើសរើស | ឥណទានវឌ្ឍនេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន១ដុំបង្វិលវឌ្ឍនេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ |
| | | | សរុបរួម | 1,414,600,000 | 1,414,600,000 | 475,774,000 | 938,826,000 | 118,943,500 | 33.6% |
| 60 | | | ការទិញ | 305,000,000 | 305,000,000 | 95,000,000 | 210,000,000 | 23,750,000 | 31.1% |
| | 6001 | | សំភារៈផ្គត់ផ្គង់និងថែទាំ | 1,000,000 | 1,000,000 | 1,000,000 | 0 | 250,000 | 100.0% |
| | | 60011 | សំភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 1,000,000 | 1,000,000 | 1,000,000 | 0 | 250,000 | 100.0% |
| | 6002 | | សំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 104,000,000 | 104,000,000 | 34,000,000 | 70,000,000 | 8,500,000 | 32.7% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 100,000,000 | 100,000,000 | 30,000,000 | 70,000,000 | 7,500,000 | 30.0% |
| | | 60022 | សៀវភៅមើល និងឯកសារ | 4,000,000 | 4,000,000 | 4,000,000 | 0 | 1,000,000 | 100.0% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 200,000,000 | 200,000,000 | 60,000,000 | 140,000,000 | 15,000,000 | 30.0% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 200,000,000 | 200,000,000 | 60,000,000 | 140,000,000 | 15,000,000 | 30.0% |
| 61 | | | សេវាខាងក្រៅ | 1,109,600,000 | 1,109,600,000 | 380,774,000 | 728,826,000 | 95,193,500 | 34.3% |
| | 6105 | | ការថែទាំនិងជួសជុល | 92,000,000 | 92,000,000 | 12,000,000 | 80,000,000 | 3,000,000 | 13.0% |
| | | 61052 | ការថែទាំជួសជុលអគារផ្សេងៗ និងប្រាសាទ | 80,000,000 | 80,000,000 | 0 | 80,000,000 | 0 | 0.0% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈនិងឧបករណ៍បច្ចេកទេស | 12,000,000 | 12,000,000 | 12,000,000 | 0 | 3,000,000 | 100.0% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 351,600,000 | 351,600,000 | 73,604,000 | 277,996,000 | 18,401,000 | 20.9% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 300,000,000 | 300,000,000 | 73,604,000 | 226,396,000 | 18,401,000 | 24.5% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 40,000,000 | 40,000,000 | 0 | 40,000,000 | 0 | 0.0% |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 11,600,000 | 11,600,000 | 0 | 11,600,000 | 0 | 0.0% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 456,000,000 | 456,000,000 | 178,290,000 | 277,710,000 | 44,572,500 | 39.1% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 137,800,000 | 137,800,000 | 56,498,000 | 81,302,000 | 14,124,500 | 41.0% |
| | | 61122 | សោហ៊ុយបេសកកម្ម | 72,400,000 | 72,400,000 | 33,304,000 | 39,096,000 | 8,326,000 | 46.0% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 245,800,000 | 245,800,000 | 88,488,000 | 157,312,000 | 22,122,000 | 36.0% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 210,000,000 | 210,000,000 | 116,880,000 | 93,120,000 | 29,220,000 | 55.7% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 28,000,000 | 28,000,000 | 14,000,000 | 14,000,000 | 3,500,000 | 50.0% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61132 | សោហ៊ុយបេសកកម្ម | 132,000,000 | 132,000,000 | 77,880,000 | 54,120,000 | 19,470,000 | 59.0% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 50,000,000 | 50,000,000 | 25,000,000 | 25,000,000 | 6,250,000 | 50.0% |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០១៧
ជ. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង

មិញ បានសុវណ្ណអានិច្ចាសីលា

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០៧ ខែ មីនា ឆ្នាំ២០១៧
ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងបរិស្ថាន ៤

ពៅ_ម៉េងហ៊ាង

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
ប្រធាននាយកដ្ឋានរដ្ឋបាល
ផែនការ និងហិរញ្ញវត្ថុ

គិន_ណារ៉ុង

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧
រដ្ឋទេយ្យករបុរេប្រទាន

ប៉ុន ចន្ទីដា

បានឃើញនិងឯកភាព
ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញនិងឯកភាព
ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៧
អគ្គនាយកគាំពារបរិស្ថាន

ហេង-ណារ៉េត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...........សហវ.........

រាជធានីភ្នំពេញ, ថ្ងៃទី.......ខែ.......ឆ្នាំ២០១៧

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការដាក់ឱ្យអនុវត្តអង្គភាពថវិកា
# របស់
# អាជ្ញាធរសវនកម្មជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ០២០/០៥ អសជ/សសរ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង នៃអាជ្ញាធរសវនកម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា

## សម្រេច

**ប្រការ១.**_

ទទួលស្គាល់ និងដាក់ឱ្យអនុវត្តអង្គភាពថវិកាចំនួន០១ " នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ " នៅអាជ្ញាធរសវនកម្មជាតិ។

**ប្រការ២.**_

គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទអាជ្ញាធរសវនកម្មជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៣.**_

ប្រកាសនេះមានប្រសិទ្ធភាពសម្រាប់ការអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**អគ្គសវនករ**
**អាជ្ញាធរសវនកម្មជាតិ**

សោម គឹមសួគ៌

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ " ដើម្បីគោរពជូនជ្រាប "
- ដូចប្រការ២ " ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តជូនអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់គោលការណ៍យន្តការនីតិវិធី និងការត្រួតពិនិត្យសម្រាប់ផ្តល់ការលើកទឹកចិត្តដោយប្រើប្រាស់ប្រាក់រង្វាន់របស់អគ្គនាយកដ្ឋានឧស្សាហ-



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
Phone : 855-23-430 225 / Fax : 855-23-430 799

កម្មហិរញ្ញវត្ថុ

- បានឃើញ ប្រកាសលេខ ១០៤១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ ១៧៨ សហវ.ប្រក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការបង្កើតមូលនិធិទ្រទ្រង់និងអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងជាសារវន្តដូចខាងក្រោម÷

- ពង្រឹង និងបង្កើនផលិតភាព គុណភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃសមិទ្ធកម្មរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ផ្តល់ការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកដោយផ្អែកលើសមិទ្ធកម្ម និងអនុលោមតាមគោលការណ៍គុណាធិបតេយ្យប្រកបដោយសមធម៌, សង្គតិភាព, តម្លាភាព និងគណនេយ្យភាព
- ជានាសុខដុមនីយកម្ម នៃគោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យនៃការផ្តល់ការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ, មន្ត្រីរាជការ, បុគ្គលិកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដោយប្រើប្រាស់ប្រាក់រង្វាន់នៅក្នុងក្របខ័ណ្ឌនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- រួមចំណែកទ្រទ្រង់ការអនុវត្តគោលនយោបាយពាក់ព័ន្ធការអភិវឌ្ឍន៍វិស័យឧស្សាហកម្មហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់គោលការណ៍, យន្តការ, នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ, មន្ត្រីរាជការ និងបុគ្គលិកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកបដោយសមធម៌, ស័ក្តិសិទ្ធភាព, ប្រសិទ្ធភាព, សង្គតិភាព, តម្លាភាព និងគណនេយ្យភាព។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះថ្នាក់ដឹកនាំ, មន្ត្រីរាជការ និងបុគ្គលិកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២
## គោលការណ៍លើកទឹកចិត្ត

**ប្រការ៤.-**

ការលើកទឹកចិត្ត សំដៅដល់ការផ្តល់ប្រាក់ឧបត្ថម្ភ, ប្រាក់រង្វាន់ ឬមូលនិធិនានាបន្ថែមលើបៀវត្សរបស់ថ្នាក់ដឹកនាំ, មន្ត្រីរាជការ និងបុគ្គលិកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដែលបានបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនប្រកបដោយផលិតភាព, គុណភាព, ស័ក្តិសិទ្ធភាព, ប្រសិទ្ធភាព និងគណនេយ្យភាព។

**ប្រការ៥.-**

ការលើកទឹកចិត្ត ត្រូវផ្តល់ជូនថ្នាក់ដឹកនាំ, មន្ត្រីរាជការ ឬបុគ្គលិកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ តាម ៤ប្រភេទ គឺប្រាក់ឧបត្ថម្ភជីវភាព, ប្រាក់ឧបត្ថម្ភមុខងារ, ប្រាក់រង្វាន់សមិទ្ធកម្ម និងមូលនិធិអភិវឌ្ឍស្ថាប័ន ដោយត្រូវផ្តល់ជូនតាមគោលការណ៍ ដូចខាងក្រោម÷

**១.ប្រាក់ឧបត្ថម្ភជីវភាព**

ប្រាក់ឧបត្ថម្ភជីវភាព ត្រូវផ្តល់ជូនថ្នាក់ដឹកនាំ, មន្ត្រីរាជការ ឬបុគ្គលិកទាំងឡាយណាដែលមកបំពេញការងារទៀងទាត់ តាមមុខងារប្រកបដោយគុណភាព និងផលិតភាព ទៅតាមសន្ទស្សន៍មេគុណសមាមាត្រ ដូចមានកំណត់ក្នុងតារាងខាងក្រោម÷

| លរ | តួនាទី | សន្ទស្សន៍មេគុណសមាមាត្រ |
|---|---|---|
| ១ | អគ្គនាយក | ៤,០០ |
| ២ | អគ្គនាយករង | ៣,៥០ |
| ៣ | ប្រធាននាយកដ្ឋាន | ៣,០០ |
| ៤ | អនុប្រធាននាយកដ្ឋាន | ២,៥០ |
| ៥ | ប្រធានការិយាល័យ | ២,០០ |
| ៦ | អនុប្រធានការិយាល័យ | ១,៥០ |
| ៧ | មន្ត្រី ឬបុគ្គលិក | ១,០០ |

ការកំណត់តម្លៃឯកតានៃសន្ទស្សន៍ គឺអាស្រ័យលើបម្រែបម្រួលនៃស្ថានភាពប្រភពធនធានសម្រាប់ផ្តល់ការលើកទឹកចិត្តដែលប្រមូលបានប្រចាំខែនីមួយៗ ឬប្រចាំឆ្នាំ។

**២.ប្រាក់ឧបត្ថម្ភមុខងារ**

ប្រាក់ឧបត្ថម្ភមុខងារ ត្រូវផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ ឬបុគ្គលិកទាំងឡាយណាដែលមកបំពេញមុខងារពាក់ព័ន្ធនឹងការងារដឹកនាំ, ការងារកែទម្រង់, ការងារសិក្សាស្រាវជ្រាវ, ការងាររៀបចំច្បាប់, បទប្បញ្ញត្តិនានា និងគោលនយោបាយការងារជំនាញចាំបាច់, ការងារចូលរួមអនុវត្តគម្រោង និងក្រុមការងារផ្សេងៗ តាមសន្ទស្សន៍មេគុណសមាមាត្រ ដូចមានកំណត់ក្នុងតារាងខាងក្រោម÷

| លរ | តួនាទី | សន្ទស្សន៍មេគុណសមាមាត្រ |
|---|---|---|
| ១ | អគ្គនាយក | ៥,០០ |
| ២ | អគ្គនាយករង | ៤,០០ |
| ៣ | ប្រធាននាយកដ្ឋាន | ៣,០០ |

| | | |
|---|---|---|
| ៤ | អនុប្រធាននាយកដ្ឋាន | ២,៥០ |
| ៥ | ប្រធានការិយាល័យ | ២,០០ |
| ៦ | អនុប្រធានការិយាល័យ | ១,៥០ |
| ៧ | មន្ត្រី ឬបុគ្គលិក | ១,០០ |

ការកំណត់តម្លៃឯកតានៃសន្ទស្សន៍ គឺអាស្រ័យលើបម្រែបម្រួលនៃស្ថានភាពប្រភពធនធានសម្រាប់ផ្តល់ការលើកទឹកចិត្តដែលប្រមូលបានប្រចាំខែនីមួយៗ ឬប្រចាំឆ្នាំ។

គម្រោងត្រូវមានទំហំការងារ ដែលត្រូវអនុវត្តក្នុងរយៈពេលចាប់ពីមួយឆ្នាំឡើងទៅ។ សម្រាប់ទំហំការងារដែលត្រូវអនុវត្តក្នុងរយៈពេលតិចជាងមួយឆ្នាំ ត្រូវបង្កើតត្រឹមតែកម្រិតនៃក្រុមការងារ។ សម្រាប់ទំហំការងារដែលត្រូវអនុវត្តក្នុងរយៈពេលតិចជាង ៣ខែ ត្រូវអនុវត្តក្នុងក្របខ័ណ្ឌការងារប្រចាំថ្ងៃធម្មតា។

ថ្នាក់ដឹកនាំ, មន្ត្រីរាជការ ឬបុគ្គលិកម្នាក់ៗអាចចូលរួមអនុវត្តការងារក្នុងគម្រោង ឬក្រុមការងារលើសពីមួយបាន គិតទាំងគម្រោងជាមួយដៃគូអភិវឌ្ឍ, គម្រោងមូលនិធិផ្សេងៗ និងសមាជិកភាពនៃក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬមន្ត្រីត្រួតពិនិត្យរដ្ឋ ប៉ុន្តែអនុញ្ញាតឱ្យទទួលប្រាក់ឧបត្ថម្ភមុខងារបានតែមួយប៉ុណ្ណោះ។

ក្នុងករណីមានជំនាញពិសេសចាំបាច់ ដែលជាក់ស្តែងតម្រូវឱ្យមានការផ្តល់ប្រាក់ឧបត្ថម្ភមុខងារខ្ពស់ គណៈកម្មការវាយតម្លៃសមិទ្ធកម្មនិងផ្តល់ការលើកទឹកចិត្តរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អាចពិនិត្យនិងសម្រេចលើសំណើផ្តល់ការលើកទឹកចិត្ត តាមសន្ទស្សន៍ណាមួយ ក្នុងចំណោមសន្ទស្សន៍ទាំង ៧ ដែលបានកំណត់ខាងលើ។

**៣.ប្រាក់រង្វាន់សមិទ្ធកម្ម**

ប្រាក់រង្វាន់សមិទ្ធកម្ម ត្រូវផ្តល់ជូនថ្នាក់ដឹកនាំ, មន្ត្រីរាជការ, បុគ្គលិក ឬនាយកដ្ឋានដែលសម្រេចបានផលលើសគោលដៅកំណត់ ដូចជាការប្រមូលចំណូលបានលើសគោលដៅកំណត់ ការបង្កើតឱ្យមានផលចំណេញថវិកាកាសម្រេចលទ្ធផលការងារបានមុនផែនការកំណត់ ការសន្សំសំចៃថវិកាបានដោយចំណាយតិចជាងគោលការណ៍កំណត់។ ប្រាក់រង្វាន់សមិទ្ធកម្ម ត្រូវផ្តល់ប្រចាំត្រីមាស ឬឆមាស ឬឆ្នាំ ទៅតាមពេលវេលាជាក់ស្តែងដែលបានកំណត់ សម្រាប់ការវាស់វែងសមិទ្ធកម្ម និងត្រូវបានកំណត់ដោយផ្អែកលើការសម្រេចលទ្ធផលការងារលើសគោលដៅដូចតទៅ÷

*១.ករណីចំណូល* ដែលបានប្រមូលលើសគោលដៅកំណត់ រង្វាន់សមិទ្ធកម្មត្រូវផ្តល់ជូនជាភាគរយនៃប្រាក់ចំណូលដែលលើសដល់សាមីនាយកដ្ឋាន ឬក្រុមការងារដែលបានអនុវត្តការប្រមូលចំណូលនោះផ្ទាល់។ ចំណូលដែលជាកម្មវត្ថុសម្រាប់ការផ្តល់រង្វាន់សមិទ្ធកម្ម គឺជាចំណូលសរុបរបស់នាយកដ្ឋានអនុវត្តផ្ទាល់នីមួយៗ ធៀបនឹងគោលដៅដែលបានកំណត់នៅក្នុងផ្ទៃក្នុងអគ្គនាយកដ្ឋាន គឺមិនមែនចំណូលសរុបរបស់អគ្គនាយកដ្ឋានធៀបនឹងច្បាប់ប្រចាំឆ្នាំ ឬ/និងប្រភេទចំណូលថ្មី ដែលរាជរដ្ឋាភិបាលបានដាក់ចេញនោះទេ។ ប្រាក់រង្វាន់សមិទ្ធកម្មនេះត្រូវបានផ្តល់ជូនប្រចាំឆ្នាំ និងត្រូវបានគិតជាភាគរយនៃប្រាក់ចំណូលលើសគោលដៅតាមអត្រា ដូចខាងក្រោម÷

- ៥០ ភាគរយ ក្នុងករណីចំណូលលើស មានចំនួនក្រោម ២០០ ០០០ ០០០(ពីររយលាន) រៀល
- ៣០ ភាគរយ ក្នុងករណីចំណូលលើស មានចំនួនចាប់ពី ២០០ ០០០ ០០០(ពីររយលាន) រៀល រហូតដល់
- ក្រោម ៥០០ ០០០ ០០០(ប្រាំរយលាន) រៀល

- ២០ ភាគរយ ក្នុងករណីចំណូលលើស មានចំនួនចាប់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល រហូតដល់ក្រោម ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល
- ១៥ ភាគរយ ក្នុងករណីចំណូលលើស មានចំនួនចាប់ពី ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល រហូតដល់ក្រោម ២ ០០០ ០០០ ០០០ (ពីរពាន់លាន) រៀល
- ១០ ភាគរយ ក្នុងករណីចំណូលលើស មានចំនួនចាប់ពី ២ ០០០ ០០០ ០០០ (ពីរពាន់លាន) រៀល រហូតដល់ក្រោម ៤ ០០០ ០០០ ០០០ (បួនពាន់លាន) រៀល
- ៥ ភាគរយ ក្នុងករណីចំណូលលើស មានចំនួនចាប់ពី ៤ ០០០ ០០០ ០០០ (បួនពាន់លាន) រៀល ឡើងទៅ។

*២.ករណីចំណាយ* ដែលត្រូវបានអនុវត្តដោយភាពសន្សំសំចៃ និងនៅសល់ពីកម្រិតចំណាយដែលបានគ្រោងនិងផ្តល់តាមគោលការណ៍កំណត់ដោយសម្រេចបានលទ្ធផលការងារតាមការរំពឹងទុក រង្វាន់សមិទ្ធកម្មត្រូវផ្តល់ជូនក្នុងអត្រា ៥០% នៃចំនួនទឹកប្រាក់ដែលនៅសល់ដល់សាមីនាយកដ្ឋាន, គម្រោង ឬក្រុមការងារដែលបានអនុវត្តការចំណាយនោះដោយផ្ទាល់។ ចំណាយដែលជាកម្មវត្ថុនៃការផ្តល់រង្វាន់សមិទ្ធកម្ម គឺជាចំណាយតាមមុខសញ្ញានីមួយៗដែលបានគ្រោង និងផ្តល់តាមគោលការណ៍កំណត់ និងដែលមានសូចនាករ និងគោលដៅសម្រាប់វាស់លទ្ធផលច្បាស់លាស់ គឺមិនមែនចំណាយសរុបរបស់នាយកដ្ឋាននោះទេ។

*៣.ករណីផែនការការងារ* ដែលត្រូវបានអនុវត្ត និងសម្រេចបានមុនកាលកំណត់ រង្វាន់សមិទ្ធកម្មត្រូវផ្តល់ជូនតាមអត្រានៃប្រាក់ឧបត្ថម្ភមុខងារសម្រាប់រយៈពេលដែលនៅសល់ដល់សាមីនាយកដ្ឋាន គម្រោង ឬក្រុមការងារដែលបានសម្រេចផែនការការងារមុនកាលកំណត់ដោយផ្ទាល់។

**៤. មូលនិធិអភិវឌ្ឍស្ថាប័ន**

មូលនិធិអភិវឌ្ឍស្ថាប័ន ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ សម្រាប់មុខសញ្ញាចំណាយដូចខាងក្រោម÷

**ក-សម្ភារៈប្រើប្រាស់÷** សម្ភារៈនិងមធ្យោបាយប្រើប្រាស់ចាំបាច់មួយចំនួនដែលជួយគាំទ្រដល់គម្រោងកម្មវិធីការងាររបស់នាយកដ្ឋានជំនាញ។

**ខ-ប្រាក់ឧបត្ថម្ភបុគ្គលិកជាប់កិច្ចសន្យា÷** ឧបត្ថម្ភជូនបុគ្គលិកជាប់កិច្ចសន្យា ឬជំនួយការ បុគ្គលិកអនាម័យតាមការចាំបាច់របស់នាយកដ្ឋាន។

**គ-ប្រាក់ឧបត្ថម្ភមន្ត្រីជួបគ្រោះថ្នាក់÷** ឧបត្ថម្ភមន្ត្រីដែលជួបគ្រោះថ្នាក់, ឈឺស្កាត់, ទទួលមរណៈភាព ឬគ្រោះមហន្តរាយផ្សេងៗ ព្រមទាំងការចំណាយចាំបាច់ផ្សេងៗ។

**ឃ-ចំណាយសម្រាប់បណ្តុះបណ្តាលធនធានមនុស្ស÷** ចំណាយសម្រាប់ការបណ្តុះបណ្តាល, ការអភិវឌ្ឍសមត្ថភាព ឬការរៀបចំបទដ្ឋានគតិយុត្តចាំបាច់ ដល់មន្ត្រីក្រោមឱវាទរបស់នាយកដ្ឋាននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ង-ប្រាក់ឧបត្ថម្ភជូនដល់ក្រសួង÷** ការឧបត្ថម្ភដល់ក្រសួង ស្ថាប័នដែលបានជួយសហការតាមតម្រូវការចាំបាច់របស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ច-ចំណាយផ្សេងៗ÷** ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ផង សម្រាប់ចំណាយចាំបាច់ផ្សេងៗតាមការកំណត់របស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

ការលើកទឹកចិត្តទាំង ៤ ប្រភេទខាងលើនេះ អាចទទួលត្រួតគ្នាបាន។

**ប្រការ៦.-**

ត្រូវបានប្រគល់សិទ្ធិជូនអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ប្រភពធនធានសម្រាប់សម្រាប់ផ្តល់ការលើកទឹកចិត្តទៅតាមសន្ទស្សន៍មេគុណសមមាត្រ និងតាមមុខសញ្ញាចំណាយដែលត្រូវបានទទួលការលើកទឹកចិត្ត ព្រមទាំងការកំណត់ថ្លៃឯកតានៃសន្ទស្សន៍ ដូចមានចែងក្នុងប្រកាសនេះ។

## ជំពូកទី៣
## ប្រភពធនធានសម្រាប់ផ្តល់ការលើកទឹកចិត្ត

**ប្រការ៧.-**

ប្រភពធនធាន សម្រាប់ផ្តល់ការលើកទឹកចិត្ត ជូនអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ មានដូចខាងក្រោម÷

- ប្រាក់រង្វាន់ ០,៣% បានមកពីប្រភពចំណូល ដែលប្រមូលបានពីកាតព្វកិច្ចចំណូលការស៊ីណូប្រចាំឆ្នាំ
- សោហ៊ុយទម្រង់ការនៃការផ្តល់ឥណទានដោយប្រើប្រាស់មូលនិធិទ្រទ្រង់និងអភិវឌ្ឍន៍វិស័យកសិកម្ម កាត់ទុកចំនួន ៥០% សម្រាប់ផ្តល់ការលើកទឹកចិត្ត
- ចំណែកនៃភាគទាន ០,៥% សម្រាប់មូលនិធិទ្រទ្រង់និងអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច តាមការសម្រេចរបស់គណៈកម្មាធិការអភិវឌ្ឍវិស័យបរធនបាលកិច្ចហិរញ្ញវត្ថុ សម្រាប់ផ្តល់ការលើកទឹកចិត្ត ដោយអនុលោមតាមបទប្បញ្ញត្តិគតិយុត្តជាធរមាន
- ថវិកាដែលបានមកពីការប្រមូលកម្រៃសេវាសាធារណៈរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ប្រភពធនធានផ្សេងទៀត ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៨.-**

ប្រភពធនធានសម្រាប់ផ្តល់ការលើកទឹកចិត្ត ដូចមានចែងក្នុងប្រការ៧ ខាងលើត្រូវបានបែងចែកតាមគោលការណ៍ដូចខាងក្រោម÷

- ប្រាក់ឧបត្ថម្ភជីវភាព ៥០%
- ប្រាក់ឧបត្ថម្ភមុខងារ ១០%
- ប្រាក់រង្វាន់សមិទ្ធកម្ម ១០%
- មូលនិធិអភិវឌ្ឍស្ថាប័ន ៣០%

## ជំពូកទី៤
## យន្តការ នីតិវិធី និងការត្រួតពិនិត្យ

**ប្រការ៩.-**

ត្រូវបង្កើតគណៈកម្មការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត ប្រចាំអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដែលសរសេរជាអក្សរកាត់ថា **គ.ស.ល.ខ.** ដែលមានសមាសភាព ដូចខាងក្រោម÷



៧

| | |
|---|---|
| ១. អគ្គនាយក | ប្រធាន |
| ២. អគ្គនាយករង ១រូប ឬច្រើនរូប | អនុប្រធាន |
| ៣. ប្រធាននាយកដ្ឋាន | សមាជិក |
| ៤. ប្រធានលេខាធិការដ្ឋាន | លេខាធិការ។ |

សមាសភាពជាក់ស្ដែងនៃគណៈកម្មការវាយតម្លៃសមិទ្ធកម្ម និងផ្ដល់ការលើកទឹកចិត្តរបស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១០.-**

គណៈកម្មការវាយតម្លៃសមិទ្ធកម្ម និងផ្ដល់ការលើកទឹកចិត្ត មានមុខងារ និងភារកិច្ចដូចខាងក្រោម÷

- រៀបចំសេចក្ដីព្រាងផែនការលើកទឹកចិត្ត ដើម្បីដាក់ជូនគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្ដល់ការលើកទឹកចិត្តនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**គ.ស.ល.**)
- ពិនិត្យសម្រេច និងអនុវត្តផែនការផ្ដល់ការលើកទឹកចិត្តរបស់អគ្គនាយកដ្ឋាន
- ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការលើកទឹកចិត្តរបស់អគ្គនាយកដ្ឋាន ប្រចាំត្រីមាស ឆមាស នឹងនៅរៀងរាល់បញ្ចប់គម្រោង ឬក្រុមការងារ ហើយត្រូវធ្វើរបាយការណ៍តាមប្រភេទនីមួយៗជូន **គ.ស.ល.** ជាទៀងទាត់ទៅតាមឥណប្រតិទិននីមួយៗ។

**ប្រការ១១.-**

ត្រូវបានបង្កើតក្រុមការងារវាយតម្លៃសមិទ្ធកម្ម និងផ្ដល់ការលើកទឹកចិត្ត នៅតាមនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| ១. ប្រធាននាយកដ្ឋាន | ប្រធាន |
| ២. អនុប្រធាននាយកដ្ឋាន ១ រូប ឬច្រើនរូប | សមាជិក |
| ៣. ប្រធានការិយាល័យ ១ រូប ឬច្រើនរូប | សមាជិក |

សមាសភាពជាក់ស្ដែងនៃក្រុមការងារវាយតម្លៃសមិទ្ធកម្ម និងផ្ដល់ការលើកទឹកចិត្តរបស់នាយកដ្ឋាននីមួយៗត្រូវកំណត់ដោយអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

**ប្រការ១២.-**

ក្រុមការងារវាយតម្លៃសមិទ្ធកម្ម និងផ្ដល់ការលើកទឹកចិត្តនៅតាមនាយកដ្ឋាននីមួយៗ មានមុខងារ និងភារកិច្ចដូចខាងក្រោម÷

- រៀបចំសេចក្ដីព្រាងផែនការលើកទឹកចិត្តរបស់នាយកដ្ឋាន ជូន **គ.ស.ល.ឧ.** ដើម្បីពិនិត្យនិងអនុម័ត
- អនុវត្តផែនការលើកទឹកចិត្តរបស់នាយកដ្ឋាន
- ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការលើកទឹកចិត្តនៃនាយកដ្ឋានរបស់ខ្លួន ដោយត្រូវធ្វើរបាយការណ៍ជូន **គ.ស.ល.ឧ.** អំពីលទ្ធផលនៃការត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាព។

**ប្រការ១៣.-**

អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំខែ ប្រចាំត្រីមាស ឬប្រចាំឆមាសដោយ

វិលេចនូវចំណូល ចំណាយឱ្យបានច្បាស់លាស់ ដើម្បីដាក់ជូនគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្តនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៤.-**

អគ្គនាយកដ្ឋានសវនកម្ម ត្រូវអនុវត្តសវនកម្មប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យអំពីសមិទ្ធកម្មនៃផែនការលើកទឹកចិត្ត ហើយរាយការណ៍ ឬផ្តល់អនុសាសន៍សវនកម្មជូន **គ.ស.ល.** ពិនិត្យនិងចាត់វិធានការក្នុងករណីចាំបាច់។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ១៥.-**

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីខែមករា ឆ្នាំ២០១៧។

**ប្រការ១៦.-**

ប្រកាសនេះ មានអានុភាពជំនួសប្រកាសលេខ ១២៦ សហវ.ប្រក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ[illegible] ឆ្នាំ២០១៧

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ ១៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ ០២០/សស.សរ/២០១៧

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារត្រួតពិនិត្យ ផ្ទៀងផ្ទាត់បញ្ជី កត់លេខអាវុធ និង ការរៀបចំទុកដាក់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ ស្តីពីវិសោធនកម្មត្រង់ទី៣ ចំណុចទី២ មាត្រា៤ និងមាត្រា២៦ នៃអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមការងារចាំបាច់របស់ក្រសួងការពារជាតិ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារ ត្រួតពិនិត្យផ្ទៀងផ្ទាត់បញ្ជី កត់លេខអាវុធ និងការរៀបចំទុកដាក់ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឧត្តមសេនីយ៍ឯក **ចៅ ភិរិទ្ធ** | អគ្គនាយករងអគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស និងជានាយក នាយកដ្ឋានយន្តយុទ្ធ | ជាប្រធាន |
| ២- ឧត្តមសេនីយ៍ទោ **តាក់ សុភាព** | នាយករង នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | អនុប្រធាន |
| ៣- ឧត្តមសេនីយ៍ទោ **អ៊ុំម សុផេង** | នាយករង នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ៤- ឧត្តមសេនីយ៍ទោ **សូ សារឹម** | នាយករង នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ៥- ឧត្តមសេនីយ៍ត្រី **ចាន់ ចំរើន** | នាយករង នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ៦- វរសេនីយ៍ឯក **ឌឹន ណារុន** | នាយការិយាល័យអាវុធ-គ្រាប់ធុនធ្ងន់ នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈ បច្ចេកទេស | សមាជិក |
| ៧- វរសេនីយ៍ឯក **វ៉េង សុផាត** | នាយការិយាល័យអាវុធ-គ្រាប់ធុនស្រាល នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈ បច្ចេកទេស | សមាជិក |
| ៨- វរសេនីយ៍ឯក **ហាយ ជៀបលី** | នាយលេខាធិការដ្ឋាន នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ៩- វរសេនីយ៍ឯក **គ្រុយ សិតថា** | ជំនួយការអគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ១០-វរសេនីយ៍ឯក **ហួរ ហាន់** | នាយការិយាល័យស្រាវជ្រាវបច្ចេកទេសយោធា នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈ បច្ចេកទេស | សមាជិក |
| ១១-វរសេនីយ៍ឯក **ណៃវ៉ាន់លី** | ជំនួយការអគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ១២-វរសេនីយ៍ឯក **សរ ចាន់តារា** | ជំនួយការអគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ១៣-វរសេនីយ៍ឯក **លឹម ពិសិដ្ឋ** | នាយការិយាល័យរោងជាងឃ្លាំងនាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ១៤-វរសេនីយ៍ឯក **ឡុង មូន** | នាយការិយាល័យផែនការនាយកដ្ឋានយន្តយុទ្ធ អគ្គនាយដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |
| ១៥-វរសេនីយ៍ឯក **ឆន ណារ៉ែន** | នាយរងការិយាល័យអាវុធ-គ្រាប់ធុនធ្ងន់ នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈ បច្ចេកទេស | សមាជិក |
| ១៦-វរសេនីយ៍ទោ **គឹម សាប៊ិន** | នាយរងការិយាល័យផែនការនាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស | សមាជិក |

១៧-វរសេនីយ៍ទោ **ដុល សាមឿន** នាយរងការិយាល័យអាវុធ-គ្រាប់ធុនធ្ងន់ នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស សមាជិក

១៨-វរសេនីយ៍ទោ **ណាត ម៉ានិត** នាយរងលេខាធិការដ្ឋាន នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស សមាជិក

១៩-វរសេនីយ៍ត្រី **ហៀង វ៉េនវិទូ** ជំនួយការការិយាល័យអាវុធ-គ្រាប់ធុនស្រាល នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស សមាជិក

២០-អនុសេនីយ៍ឯក **យឹម គឹមយន** ជំនួយការការិយាល័យអាវុធ-គ្រាប់ធុនធ្ងន់ នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស សមាជិក

២១-អនុសេនីយ៍ទោ **សិទ្ធ គង់មុន្នី** ជំនួយការការិយាល័យអាវុធ-គ្រាប់ធុនធ្ងន់ នាយកដ្ឋានយន្តយុទ្ធ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស សមាជិក

២២-តំណាងរោងជាងជួសជុលចម្រុះលង្វែក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស ចំនួន ២ នាក់ សមាជិក

២៣-តំណាងទីចាត់ការបច្ចេកទេស អគ្គបញ្ជាការដ្ឋាន ចំនួន ៣នាក់ សមាជិក

២៤- តំណាងការិយាល័យបច្ចេកទេសកងទ័ពជើងគោក ចំនួន ៣នាក់ សមាជិក

២៥-តំណាងការិយាល័យអាវុធ-គ្រាប់ស្នងការបច្ចេកទេសកងទ័ពជើងទឹក ចំនួន ២នាក់ សមាជិក

២៦-តំណាងការិយាល័យអាវុធ-គ្រាប់បញ្ជាការដ្ឋានការពារកោះធ្លេរ ចំនួន ២នាក់ សមាជិក

២៧-តំណាងការិយាល័យអាវុធ-គ្រាប់មូលដ្ឋានរាមកងទ័ពជើងទឹក ចំនួន ២នាក់ សមាជិក

ឯកឧត្តម មេបញ្ជាការ និង ជំនាញគ្រប់កងឯកភាព សមាជិក

**ប្រការ២.-**

ក្រុមការងារមានភារកិច្ចដូចខាងក្រោម៖

-ធ្វើជាសេនាធិការជូនក្រសួងការពារជាតិ លើការងារត្រួតពិនិត្យ ផ្ទៀងផ្ទាត់បញ្ជីកត់លេខអាវុធ និងរៀបចំទុកដាក់អាវុធគ្រាប់ដែលមាន និងកំពុងប្រើប្រាស់ទូទាំងកងយោធពលខេមរភូមិន្ទ

-រៀបចំកម្មវិធីការងារអនុវត្ត ឲ្យបានទាន់ពេលវេលា នៃការប្រជុំក្រុមការងារ តាមរបៀបវារៈកំណត់ ហើយនិងជូនដំណឹងដល់ក្រុមការងារដែលពាក់ព័ន្ធ

-ធ្វើការងារមួយចំនួនទៀតតាមការប្រគល់របស់ប្រធាន ក្រោយពេលត្រួតពិនិត្យការងារចប់ ត្រូវប្រជុំបូកសរុប និងរាយការណ៍ជូនក្រសួងការពារជាតិ ។

**ប្រការ៣.-**

អនុប្រធាននិងសមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៤.-**

ក្រុមការងារមានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស ។

**ប្រការ៥.-**

អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ មេបញ្ជាការកងទ័ពជើងគោក ជើងទឹក ជើងអាកាស គ្រប់អគ្គនាយក អគ្គនាយកដ្ឋាន នាយក នាយកដ្ឋាន ប្រធានស្ថាប័នចំណុះក្រសួងការពារជាតិនិងមេបញ្ជាការគ្រប់កងឯកភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍.ទៀ-បាញ់

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងការពារជាតិ
-ដូចប្រការ៥
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្តីការគណៈរដ្ឋមន្ត្រី